ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន
និងយុវនីតិសម្បទា

របាយការណ៍
ឫកសរុបលទ្ធផលការងារប្រចាំខែមេសា ឆ្នាំ ២០១៤ និងទិសដៅអនុវត្តបន្ត

ដើម្បីឈានទៅសម្រេចទិសដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ទប់ស្កាត់ភាពងាយរងគ្រោះនៅក្នុងសង្គម រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដែលប្រកាសដាក់ឲ្យប្រើដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣។ ត្រង់មុំទី៣ និងមុំទី៤ នៃចតុកោណទី៤ ស្តីពីការអភិវឌ្ឍប្រព័ន្ធសុវត្ថិភាពសង្គម និងការជំរុញគោលនយោបាយជាតិប្រជាជន និងសមភាពយេនឌ័រ បានបង្ហាញយ៉ាងច្បាស់អំពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការជួយដល់ជនរងគ្រោះ និងងាយរងគ្រោះគ្រប់ប្រភេទក្នុងសង្គម ជាពិសេសកុមារកំព្រា កុមារងាយរងគ្រោះ ស្ត្រី ជនចាស់ជរា ជនពិការ អតីតយុទ្ធជន និងអតីតមន្ត្រីរាជការស៊ីវិល។

ដើម្បីរួមចំណែកក្នុងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ ជាពិសេស ជនរងគ្រោះ និងងាយរងគ្រោះ ក្រសួង ស.អ.យ បានដាក់ចេញនូវយុទ្ធសាស្ត្រ ៣យ៉ាង និងកម្មវិធីអាទិភាពចំនួន ៨ ចំណុច ជំហានទី៣ គឺ (ក).យុទ្ធសាស្ត្រ ៣យ៉ាង រួមមាន (១). បង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម (២). ពង្រឹងពង្រីកប្រព័ន្ធសន្តិសុខសង្គម និង(៣).ពង្រឹងសមត្ថភាពស្ថាប័ន និងកៀរគរប្រភពធនធានទាំងផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ និង(ខ).កម្មវិធីអាទិភាព ៨ចំណុច គឺ (១).អភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះនិងងាយរងគ្រោះ និងកិច្ចការគ្រួសារ (២).អភិវឌ្ឍសុខុមាលភាពកុមារ និងយុវនីតិសម្បទា (៣).អភិវឌ្ឍសុខុមាលភាពជនពិការ (៤).អភិវឌ្ឍសុខុមាលភាពមនុស្សចាស់ (៥).អភិវឌ្ឍរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (៦).អភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន (៧).បង្កើតប្រព័ន្ធសន្តិសុខសង្គមទូលំទូលាយសម្រាប់ប្រជាជនកម្ពុជា និង(៨).អភិវឌ្ឍសមត្ថភាពស្ថាប័ន និងពង្រឹងភាពជាដៃគូ។

ជាអាទិ៍ក្នុងខែមេសា ឆ្នាំ២០១៤នេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាអនុវត្តសម្រេចបានលទ្ធផលដូចខាងក្រោម៖

I-លទ្ធផលការងារ

១.ការងារអាទិភាពទី ១
អភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះនិងងាយរងគ្រោះ និងកិច្ចការគ្រួសារ
ក-ការងារសង្គ្រោះបន្ទាន់ដល់ក្រុមជនរងគ្រោះ និងងាយរងគ្រោះ

-ជនរងគ្រោះ និងងាយរងគ្រោះប្រមាណ ១៣២នាក់ បានទទួលការឧបត្ថម្ភគាំទ្រ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ

-បានស្រង់ស្ថិតិប្រជាជនទីទ័លក្រ និងរងគ្រោះមហន្តរាយផ្សេងៗសរុបប្រមាណចំនួន ៦៦៨ គ្រួសារ ក្នុងនោះ ខេត្តកែបចំនួន ៦៥៦គ្រួសារ សៀមរាបចំនួន ០៦គ្រួសារ និងខេត្តកំពតចំនួន ០៦គ្រួសារ។

ខ-ការងារជនអនាថា

-បានទទួលជនអនាថាចំនួន ២០នាក់ ក្នុងនោះ រាជធានីភ្នំពេញចំនួន ១១នាក់ និងខេត្តកំពតចំនួន ០៩នាក់

-មន្ទីរ ស.អ.យ ខេត្តស្វាយរៀងបានទទួលប្រជាពលរដ្ឋចំណាកស្រុកពីប្រទេសវៀតណាមចំនួន ០៣លើក សរុបចំនួន ១០២នាក់ ស្រីចំនួន ៦៥នាក់

-មន្ទីរ ស.អ.យ រាជធានីភ្នំពេញ បានគ្រប់គ្រងជនក្រីក្រគ្មានទីពឹងចំនួន ៧២នាក់ ស្រី ៤០នាក់។

គ-ការទប់ស្កាត់ការរីករាលដាលជំងឺហ៊ីវ អេដស៍

-បានជួយឧបត្ថម្ភគាំទ្រដល់កុមាររងគ្រោះ និងរងផលប៉ះពាល់ដោយមេរោគអេដស៍ចំនួន ១.៧៥៧ នាក់ ក្នុងនោះ ខេត្តកែបចំនួន ២៧នាក់ ស្វាយរៀងចំនួន ៣២នាក់ និងខេត្តសៀមរាបចំនួន ១.៦៩៨នាក់។ ដោយឡែក អង្គការសង្គ្រោះជនអស់សង្ឃឹមបានជួយឧបត្ថម្ភជាអង្ករ ម្ហូប និងសោហ៊ុយធ្វើដំណើរទៅមន្ទីរពេទ្យដល់អ្នកជំងឺអេដស៍តាមផ្ទះចំនួន ០៨គ្រួសារ។

យ-ការងារកិច្ចការគ្រួសារ និងយេនឌ័រ

-បានធ្វើបច្ចុប្បន្នភាពសមាសភាពគណៈកម្មការជាតិពិគ្រោះយោបល់គោលនយោបាយចំពោះគ្រួសារ

-បានចូលរួមកិច្ចប្រជុំ និងសិក្ខាសាលាផ្សេងៗ។

ង-ការងារប្រឆាំងការជួញដូរមនុស្ស និងការធ្វើសមាហរណកម្មជនរងគ្រោះ

ង-១-ការប្រឆាំងការជួញដូរមនុស្ស

-បានពិនិត្យកែសម្រួលសេចក្តីព្រាងគោលការណ៍ណែនាំ ស្តីពីការកំណត់អត្តសញ្ញាណ និងការបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស

-បានពិនិត្យកែសម្រួលសេចក្តីព្រាងឧបករណ៍ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

ង-២-ការងារសមាហរណកម្ម និងកិច្ចការពារជនរងគ្រោះ

-បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន ០១នាក់ ពីអង្គការរតនៈអន្តរជាតិ មកអប់រំ ណែនាំ ពិគ្រោះយោបល់ បញ្ជូនទៅស្តារនីតិសម្បទានិងបណ្តុះបណ្តាលវិជ្ជាជីវៈនៅតាមមណ្ឌលអង្គការទឹកចិត្តម្តាយ។

ង-៣-ការងារមណ្ឌលសំចតប៉ោយប៉ែត

-ទទួលជនរងគ្រោះដោយសារការជួញដូរ តាមរយៈការធ្វើមាតុភូមិនិវត្តន៍ចំនួន ២០នាក់ ស្រី ០២នាក់ និងបានបញ្ជូនទៅស្នាក់នៅក្នុងអង្គការកុមាររីករាយចំនួន ០៧នាក់ អង្គការតំណក់ទឹកចំនួន ០៦នាក់ និងអង្គការគ្រួសារថ្មីប៉ោយប៉ែតចំនួន ០៥នាក់ និងសមាហរណកម្មទៅសហគមន៍វិញចំនួន ០២នាក់

-បានផ្តល់សម្លៀកបំពាក់ និងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃដល់ជនរងគ្រោះនិរទេសពីប្រទេសថៃចំនួន ០៣នាក់ ដោយក្នុងម្នាក់ទទួលបាន ខោ ២ អាវយឺត ២ កន្សែងពោះគោ ១ ខោទ្រនាប់ ២ ស្បែកជើងផ្ទាត់ ១គូ សាប៊ូកក់សក់ ១ដប ថ្នាំដុសធ្មេញ ១ ច្រាសដុសធ្មេញ ១ សាប៊ូដុំ ១ សាប៊ូម្សៅ ១កញ្ចប់ និងថង់ដាក់សម្ភារៈ ១

-តាមដានអតិថិជនចំនួន ០៤ករណី។

២.ការងារអាទិភាពទី ២

ពង្រឹង ពង្រីកសេវាសុខុមាលភាពកុមារ និងយុវនីតិសម្បទា

ក-ការងារសុខុមាលភាពកុមារ

-សិទ្ធិជាមូលដ្ឋានទាំង ៤ របស់កុមារត្រូវបានជ្រួតជ្រាបទៅក្នុងសហគមន៍ តាមរយៈកម្មវិធីផ្សព្វផ្សាយជាច្រើនរបស់រដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាលនានា

-បាននិងកំពុងពិនិត្យកែសម្រួលសេចក្តីព្រាងអនុក្រឹត្យ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ

-បានបណ្តុះបណ្តាល ស្តីពីនីតិវិធីអនុវត្តគោលនយោបាយ ស្តីពីការថែទាំជំនួសចំពោះកុមារដល់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងមន្ត្រី ស.អ.យ ស្រុក នៅខេត្តពោធ៍សាត់ ដោយមានអ្នកចូលរួមចំនួន ៣៤នាក់

-បានពិនិត្យ កែសម្រួល និងធ្វើបច្ចុប្បន្នភាពព័ត៌មានគេហទំព័ររបស់ក្រុមការងារថ្នាក់ជាតិពហុវិស័យ ស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះ (ក.ជ.ក.រ) ដែលមានឈ្មោះថា www.novctf.gov.kh។

ក-១-ការងារមជ្ឈមណ្ឌលកុមារកំព្រា និងការថែទាំកុមារ

-រហូតមកដល់បច្ចុប្បន្នមណ្ឌលកុមារកំព្រាមានចំនួន ២២៥កន្លែង បានទទួលកុមារកំព្រា ទារកកំព្រាកុមារពិការសរុបចំនួន ១១.៨៥៦នាក់ ក្នុងនោះមណ្ឌលរបស់រដ្ឋមាន ២២កន្លែង បានទទួលចិញ្ចឹមកុមារ

កំព្រាចំនួន ២.២៤៤នាក់។ កុមារកំព្រាសុទ្ធតែទទួលនូវសេវាស្នាក់នៅ អប់រំ ចិញ្ចឹមបីបាច់ថែរក្សា បង្ក លក្ខណៈឱ្យរៀនសូត្រចំណេះដឹងទូទៅ បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងធ្វើសមាហរណកម្មទៅរស់នៅ សហគមន៍វិញ។ មជ្ឈមណ្ឌលកុមារកំព្រារបស់រដ្ឋចំនួន ៣កន្លែង បានទទួលការជួយឧបត្ថម្ភបន្ថែមពី សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ក្នុងនោះមាន៖ មណ្ឌល គៀនឃ្លាំង អង្ករ ១២គោន ប្រាក់ ២៤.000.000រៀល/ឆ្នាំ មណ្ឌលកម្ពុជា-បារាំង-ហុងគ្រី អង្ករ ១២គោន ប្រាក់ ១២លានរៀល/ឆ្នាំ និងមណ្ឌលកូលាប ទី ៤ ទឹកប្រាក់ ១២លានរៀល/ឆ្នាំ។ ក្រៅពីការថែទាំក្នុង មណ្ឌលកុមារកំព្រា កុមារងាយរងគ្រោះជាច្រើនទៀត បានទទួលចិញ្ចឹមថែទាំ និងផ្តល់សេវាឧបត្ថម្ភផ្សេងៗ ទៀត នៅក្នុងសហគមន៍ដោយសាច់ញាតិ គ្រួសារធម៌ គ្រួសារចិញ្ចឹម នៅតាមវត្តអារាម និងតាមកម្មវិធី ផ្សេងៗទៀតរបស់អង្គការជាតិ និងអន្តរជាតិនានា

-បានចេញប្រកាសលុបឈ្មោះកុមារពីបញ្ជីបើកប្រាក់គោលនយោបាយចំនួន ៣០នាក់ និងប្រកាស បញ្ជូលកុមារឱ្យស្នាក់នៅក្នុងមណ្ឌលរដ្ឋ និងទទួលរបបគោលនយោបាយចំនួន ២៩នាក់

-បានពិនិត្យ កែសម្រួលសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ។

ក-២-ការងារថែទាំជំនួសចំពោះកុមារ និងអធិការកិច្ច

-បានរៀបចំគោលការណ៍ណែនាំ និងឧបករណ៍នានា សម្រាប់អនុវត្តប្រកាសស្តីពីនីតិវិធីអនុវត្ត គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ

-បានរៀបចំរបាយការណ៍ ស្តីពីការចុះប៉ាន់ប្រមាណគ្រួសារកុមារកំព្រាដែលរស់នៅក្នុងមណ្ឌល កុមារកំព្រាគៀនឃ្លាំង។

ក-៣-ការងារស្នុំកូនចិញ្ចឹម

-បានរៀបចំផែនការសកម្មភាពរបស់រដ្ឋបាលស្នុំកូនអន្តរប្រទេសឆ្នាំ២០១៤

-បានទទួលរបាយការណ៍ស្តីពីការវិវឌ្ឍរបស់កុមារចំនួន ០២ករណី ពីប្រទេសកាណាដា

-បានចេញប្រកាសលេខ ១២៣០ ស.អ.យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលស្នុំកូន អន្តរប្រទេស

-បានបង្កើត និងកែសម្រួលទម្រង់នានានៃដំណើរការស្នុំកូនអន្តរប្រទេស ដូចជា កិច្ចព្រមព្រៀង ស្តីពីការកំណត់ចំនួនទីភ្នាក់ងារស្នុំកូនអន្តរប្រទេស កិច្ចសន្យារវាងរដ្ឋបាលស្នុំកូនអន្តរប្រទេសនិងទីភ្នាក់ងារ ស្នុំកូនអន្តរប្រទេស ទម្រង់ប្រើប្រាស់ជាមួយទីភ្នាក់ងារស្នុំកូនអន្តរប្រទេស ទម្រង់ប្រើប្រាស់ជាមួយឪពុក ម្តាយចិញ្ចឹម ទម្រង់ប្រើប្រាស់ជាមួយកុមារ និងទម្រង់លិខិតនានារបស់រដ្ឋបាលស្នុំកូនអន្តរប្រទេស។

ខ-ការងារយុវនីតិសម្បទា

ខ-១-ការអប់រំ ទប់ស្កាត់កុមារ យុវជនប្រព្រឹត្តបទល្មើស និងសេពគ្រឿងញៀន

-កែសម្រួលសេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធី និងវិធានការនៃការព្យាបាល ការគ្រប់គ្រង និងការ ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

-បានកែសម្រួលសេចក្តីព្រាងអនុក្រឹត្យ ស្តីពីនីតិវិធីសម្រាប់វិធីសាស្ត្រស្តារនីតិសម្បទា និងការគ្រប់ គ្រងវិធានការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

-បានពិនិត្យ កែសម្រួលសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិជាតិ សម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន

-បានពិនិត្យ កែសម្រួលគោលការណ៍ណែនាំ ស្តីពីនីតិវិធីនៃការទទួលជនរងគ្រោះដោយសារការ ប្រើប្រាស់គ្រឿងញៀន។

ខ-២-ការការពារអនីតិជន

-បាននិងកំពុងជំរុញសុំការឯកភាពពីទីស្តីការគណៈរដ្ឋមន្ត្រី លើសេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌ អនីតិជន

ខ-៣-ការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

-មន្ទីរ ស.អ.យ រាជធានីភ្នំពេញបានទទួលជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនចំនួន ៤២នាក់ មកស្នាក់នៅ អប់រំ កែប្រែ ស្តារនីតិសម្បទា និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-គិតមកដល់ខែមេសា ឆ្នាំ២០១៤ ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀននៅសល់ជាក់ស្តែងនៅក្នុងមណ្ឌលចំនួន ៩០២នាក់ ក្នុងនោះ មជ្ឈមណ្ឌលជិវិតថ្មីភ្នំបាក់ខេត្តបន្ទាយមានជ័យចំនួន ១០៩នាក់ មណ្តាលឱកាសខ្ញុំរាជធានីភ្នំពេញចំនួន ៤០៨នាក់ មជ្ឈមណ្ឌលពិភពថ្មីក្តីសង្ឃឹមខេត្តបាត់ដំបងចំនួន ៤៧នាក់ មជ្ឈមណ្ឌលបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តបាត់ដំបងចំនួន ១០៧នាក់ មជ្ឈមណ្ឌលបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យចំនួន ១៦៥នាក់ មជ្ឈមណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនខេត្តសៀមរាបចំនួន ៣១នាក់ និងមជ្ឈមណ្ឌលបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តព្រះសីហនុចំនួន ៣៥នាក់។

គ-ការងារក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក)

-បានបញ្ចប់ទស្សនាទាន និងគម្រោងថវិកាសម្រាប់ការសិក្សា ស្រាវជ្រាវក្រោមប្រធានបទ "ការបោះបង់ការសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិ" និងរៀបចំព្រឹត្តិបត្រព័ត៌មានស្ថានភាពកុមារលេខ៣ របស់ ក.ជ.ក

-បាននឹងកំពុងរៀបចំបង្កើតអនុគណៈកម្មការចំនួន ០២ គឺអនុគណៈកម្មការច្បាប់ និងគោលនយោបាយពាក់ព័ន្ធនឹងការការពារកុមារ និងអនុគណៈកម្មការពិនិត្យតាមដាន និងធ្វើរបាយការណ៍

-បានពិនិត្យកែសម្រួលសៀវភៅសិក្សាស្តីពីសិទ្ធិកុមារ-
បានរៀបចំឯកសារត្រៀមសម្រាប់រៀបចំទិវាកុមារអន្តរជាតិ ១មិថុនា ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០១៤

-ធ្វើបច្ចុប្បន្នភាពជាប្រចាំ គេហទំព័រ ក.ជ.ក (www.cncc.gov.kh)

-បានសម្របសម្រួលជាមួយក្រុមការងារដើម្បីកុមារក្រសួងព័ត៌មានដើម្បីរៀបចំវេទិកាតុមូលតាមទូរទស្សន៍សម្រាប់អបអរសាទរទិវកុមារអន្តរជាតិ ១មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០១៤

-បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការយល់ដឹងអំពីស្ថិតិ និងការតាមដាន វាយតម្លៃ រយៈពេល ៤ថ្ងៃដែលមានអ្នកចូលរួមជាមន្ត្រីក្រសួង ស.អ.យ និងមន្ត្រីអគ្គលេខាធិការដ្ឋាន ក.ជ.ក សរុបចំនួន ៣៥នាក់

-រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ៣៨២ អនក្រ.តត ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៤ ស្តីពីការតែងតាំងសមាសភពក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

-បានរៀបចំផែនការយុទ្ធសាស្ត្រឆ្នាំ២០១៤-២០១៨ របស់ ក.ជ.ក។

គ-ការងារពហុវិស័យស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះ

-បានផ្សព្វផ្សាយបទដ្ឋានគោលការណ៍ណែនាំ ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃលើសេវាមូលដ្ឋានដែលផ្តល់ឲ្យកុមារកំព្រា និងកុមារងាយរងគ្រោះដល់មន្ត្រី ស.អ.យ ស្រុក និង គ.ក.ន.ក ក្នុងខេត្តពោធ៍សាត់ និងខេត្តតាកែវ មានអ្នកចូលរួមសរុបចំនួន ៨០នាក់។

-បានរៀបចំសេចក្តីព្រាងប្រកាសស្តីពីក្រុមការងារមូលនិធិសកលនៃក្រសួង ស.អ.យ។

៣.ការងារអាទិភាពទី៣

ពង្រឹង ពង្រីកសេវាសុខុមាលភាពជនពិការ និងស្តារលទ្ធភាពពលកម្ម

ក-ការងារសុខុមាលភាពជនពិការ

-បានចូលរួមជាវាគ្មិនក្នុងសិក្ខាសាលាស្តីពីការដាក់បញ្ចូលបញ្ហាពិការភាពក្នុងផែនការអភិវឌ្ឍន៍ជនពិការជនបទរបស់អង្គការ CDMD នៅខេត្តតាកែវ

-បានចូលរួមសន្និសីទផែនការ ស្តីពីអាស៊ានដើម្បីវាយតម្លៃជនពិការ ពីថ្ងៃទី១-៥ ខែមេសា ឆ្នាំ២០១៤ នៅទីក្រុងមានីឡា សាធារណៈរដ្ឋហ្វីលីពីន

-រៀបចំនីតិវិធី និងលិខិតស្នាមផ្សេងៗដែលពាក់ព័ន្ធនឹងរដ្ឋបាលសិទ្ធិជនពិការ

-បានពិនិត្យ កែសម្រួលសេចក្តីព្រាងអនុក្រឹត្យ ស្តីពីរបបគោលនយោបាយចំពោះជនពិការដែលស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ

-រៀបចំនីតិវិធីសម្រាប់ធ្វើអធិការកិច្ចតាមក្រសួង ស្ថាប័នពាក់ព័ន្ធ ស្តីពីការជ្រើសរើសជនពិការចូលបម្រើការងារ។

ខ-ការងារបណ្តុះបណ្តាលវិជ្ជាជីវ: និងមុខរបរ

-មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមពោធិ៍សែនជ័យ និងបន្ទាយព្រាបបានបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនពិការបានចំនួន ១៦៣នាក់ ស្រី ៣៨នាក់ លើ ៧មុខជំនាញ ក្នុងនោះ មានជំនាញកសិកម្មចំនួន ២២នាក់ អេឡិចត្រូនិចចំនួន ៤២នាក់ ជួសជុលម៉ាស៊ីនចំនួន ៣២នាក់ កាត់ដេរសម្លៀកបំពាក់ចំនួន ៣២នាក់ ជួសជុលម៉ូតូចំនួន ១៥នាក់ កាត់ដេរស្បែកជើងចំនួន ០៧នាក់ ចម្លាក់ចំនួន ០៨នាក់ និងផ្នែកជួសជុលទូរស័ព្ទចំនួន ០៩នាក់។ ទន្ទឹមនេះ បានដោះស្រាយការងារជូនជនពិការបានចំនួន ២៨នាក់

-បាននិងកំពុងរៀបចំលិខិតបទដ្ឋានសម្រាប់ការអនុវត្តអនុក្រឹត្យស្តីពីការកំណត់អត្រា និងបែបបទនៃការជ្រើសរើសជនពិការចូលបម្រើការងារ។

ค-ការងារមូលនិធិជនពិការ

-ធ្វើបច្ចុប្បន្នភាពគេហទំព័រមូលនិធិជនពិការ ដែលមានឈ្មោះថា www.pwdf.gov.kh

-បានរៀបចំប្រកាសស្តីពីការតែងតាំង និងប្រគល់ភារកិច្ចមន្ត្រីរាជការនៃសាខាមូលនិធិជនពិការខេត្តបាត់ដំបង់ចំនួន ១៤រូប

-បានរៀបចំសេចក្តីសម្រេចតែងតាំងបុគ្គលិកជាប់កិច្ចសន្យាចំនួន ១៨រូប នៃមូលនិធិជនពិការថ្នាក់កណ្តាល និងសាខាមូលនិធិជនពិការខេត្តតាកែវ និងខេត្តបាត់ដំបង

-បានពិនិត្យ កែសម្រួលសេចក្តីព្រាងប្រកាស ស្តីពីការអនុវត្តរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍។

ค-១-ការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ

-ក្នុងខែមេសា ឆ្នាំ២០១៤នេះ មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម និងរោងជាងទាំង ១៥កន្លែង បានផ្តល់សេវាស្តារលទ្ធភាពគ្រប់ប្រភេទជូនជនពិការបានចំនួន ៨.២៩៩នាក់ ក្នុងនោះ ស្រីចំនួន ៣.៨៨៩នាក់។ ទន្ទឹមនេះ ជនពិការដែលមកទទួលសេវាពីមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មក៏បានទទួលការឧបត្ថម្ភជាប្រាក់អាហារ និងថ្លៃធ្វើដំណើរទៅមកផងដែរ

-បានផលិតឧបករណ៍សិប្បនិម្មិត និងរណាបចំនួន ១.៤៤៦គ្រឿង និងបែងចែកទៅតាមមជ្ឈមណ្ឌលស្តារចំនួន ១.០៧៣គ្រឿង។

ค-១-១-ការស្តារលទ្ធភាពពលកម្មកាយសម្បទា

បានផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាចំនួន ២.០៨២នាក់ ស្រីចំនួន ៥៩៦នាក់ និងជនពិការដោយសារមីនចំនួន ៥៥១នាក់

ค-១-២-ការស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ

បានផ្តល់សេវាស្តារវេជ្ជសាស្ត្រជូនជនពិការចំនួន ៦.៥២៤នាក់ ស្រីចំនួន ៣.២៩៣នាក់។

៤.ការងារអាទិភាពទី៤

ពង្រឹង ពង្រីករបបសន្តិសុខសង្គម សុខុមាលភាពមនុស្សចាស់ មន្ត្រីរាជការស៊ីវិល និងប្រជាជនទូទៅ

ก-ការងារបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស)

-បានកែសម្រួលដំឡើងរបបឧបត្ថម្ភគោលនយោបាយជូនអតីតមន្ត្រីរាជការស៊ីវិល

-បើកប្រាក់របបសន្តិសុខសង្គមជូនគ្រួសារសពនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈចំនួន ២៥៣នាក់

-ចុះបើកផ្តល់ប្រាក់សោធនប្រចាំខែជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈដែលមានជំងឺដល់គេហដ្ឋានចំនួន ០៧នាក់

-បើកផ្តល់ប្រាក់សោធនតាមប្រព័ន្ធធនាគារជូនសិទ្ធិវន្តថ្មីចំនួន ៨៣៣នាក់

-បើកផ្តល់ប្រាក់រំលឹកសោធនជូនសិទ្ធិវន្តចំនួន ២៨២នាក់

-បានធ្វើបច្ចុប្បន្នភាពសិទ្ធិវន្តបញ្ចូលក្នុងប្រព័ន្ធព័ត៌មានវិទ្យាសរុបចំនួន ៣៤១នាក់ ក្នុងនោះ និវត្តជនចំនួន ៣៣៨នាក់ និងជនបាត់បង់សម្បទាវិជ្ជាជីវៈចំនួន ០៣នាក់ និងអ្នកនៅក្នុងបន្ទុកសរុបចំនួន ៣១៤នាក់

-បានពិនិត្យផ្ទៀងផ្ទាត់ និងធ្វើបច្ចុប្បន្នភាពជូនសិទ្ធិវន្តនៃ ប.ជ.ស ជាប្រចាំថ្ងៃ និងផ្តល់សលាកបត្រជូនសិទ្ធិវន្តដែលទើបនឹងចូលនិវត្តន៍

-បានប្រគល់សៀវភៅធនាគារជូនសិទ្ធិវន្តចំនួន ៤៦នាក់

-បានរៀបចំបែបបទដាក់មន្ត្រីឲ្យចូលនិវត្តចំនួន ១២៧នាក់

-បានរៀបចំបែបបទឧបត្ថម្ភប្រាក់គោលនយោបាយប្រចាំខែជូនប្រពន្ធនៅក្នុងបន្ទុកចំនួន ៨៨នាក់ និងកូននៅក្នុងបន្ទុកចំនួន ៣៥នាក់

-លុបឈ្មោះសពនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈចំនួន ១៣១នាក់

-កែតម្រូវកាំប្រាក់ជូននិវត្តជនចំនួន ០៣នាក់

-ផ្ទេរការគ្រប់គ្រងនិវត្តជនពីខេត្តបាត់ដំបងទៅខេត្តកណ្តាលចំនួន ០១នាក់

-ត្រួតពិនិត្យឯកសារ និងបំពេញទម្រង់បែបបទបើកផ្តល់របបសន្តិសុខសង្គមជូនគ្រួសារសពនិវត្តជន និងសពជនបាត់បង់សម្បទាវិជ្ជាជីវៈនៅរាជធានី ខេត្តបានចំនួន ៩៣នាក់

-ចុះត្រួតពិនិត្យការបើកប្រាក់គោលនយោបាយរបបសន្តិសុខសង្គមជូនគ្រួសារសពនិវត្តជន សពជនបាត់បង់សម្បទាវិជ្ជាជីវៈនៅរាជធានីភ្នំពេញចំនួន ១៦៣គ្រួសារ

-បានរៀបចំកិច្ចសន្យាស្តីពីការផ្ទេរសិទ្ធិសម្រាប់និវត្តជន ឬជនបាត់បង់សម្បទាវិជ្ជាជីវៈ ដើម្បីផ្ទេរសិទ្ធិបើកប្រាក់គោលនយោបាយសោធននៅពេលមានជំងឺ និងបានចុះពិនិត្យជាក់ស្តែងនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈដែលមានជំងឺសុំផ្ទេរសិទ្ធិនៅតាមរាជធានី ខេត្តចំនួន ១២២នាក់

-បានចុះត្រួតពិនិត្យការបើកគោលនយោបាយសោធនប្រចាំខែជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈចំនួន ០៥នាក់ ដែលមានជំងឺដល់គេហដ្ឋាននៅរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ ខេត្តស្វាយរៀង និងខេត្តព្រៃវែង

-បានបង្កើតគេហទំព័ររបស់ ប.ជ.ស ដែលមានឈ្មោះថា www.nssfc.gov.kh។

ខ-ការងារប្រព័ន្ធសន្តិសុខសង្គមទូលំទូលាយសម្រាប់ប្រជាជនទូទៅ

ក្រសួងបាន និងកំពុងសិក្សាស្រាវជ្រាវឯកសារនានា ដើម្បីរៀបចំបង្កើតប្រព័ន្ធសន្តិសុខសង្គមទូលំទូលាយសម្រាប់មជ្ឈដ្ឋាននានា និងប្រជាជនទូទៅ

គ-ការងារសុខុមាលភាពមនុស្សចាស់

-គិតមកដល់ខែមេសា ឆ្នាំ២០១៤នេះ សមាគមមនុស្សចាស់សរុបចំនួន ៥៦៩សមាគម និងសមាជិកសរុបចំនួន ១៨៣.៤៣១នាក់ ត្រូវបានបង្កើតនៅតាមរាជធានី ខេត្តទាំង ២៤ សំដៅជួយគ្នាទៅវិញទៅមកនៅតាមសហគមន៍ សកម្មភាពសំខាន់ៗរបស់សមាគមគឺការចុះសួរសុខទុក្ខសមាជិកមានជំងឺ ការរៀបចំបុណ្យសព និងការលើកកម្ពស់សុខុមាលភាព

-មន្ទីរ ស.អ.យ ខេត្តកែប បាននាំយកថវិកាមរណៈសង្គ្រោះជួយឧបត្ថម្ភគ្រួសារសពចំនួន ០៦គ្រួសារ ដោយ ០១គ្រួសារទទួលបានថវិកាចំនួន ១.៦០៥.០០០រ

-មន្ទីរ ស.អ.យ ខេត្តបន្ទាយមានជ័យបានសហការជាមួយអង្គការជួយជនចាស់ជរាកម្ពុជា និងអង្គការធម្មយាត្រាបង្កើតសមាគមមនុស្សចាស់បានចំនួន ៥៣សមាគម មានសមាជិកសរុបចំនួន ២.៥៨៩នាក់

-រៀបចំសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការថែទាំមនុស្សចាស់នៅតាមលំនៅឋាននៅកម្ពុជា

-បានរៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់។

៥.ការងារអាទិភាពទី៥

ពង្រឹង ពង្រីករបបសន្តិសុខសង្គម និងសុខុមាលភាពនៃអតីតយុទ្ធជន

ក-បេឡាជាតិអតីតយុទ្ធជន (ប.ជ.អ)

-បានកែសម្រួល និងដំឡើងប្រាក់សោធន និងប្រាក់ឧបត្ថម្ភផ្សេងៗជូនអតីតយុទ្ធជន និងគ្រួសារជាប្រចាំ

-បានធ្វើបច្ចុប្បន្នភាពអតីតយុទ្ធជន និងគ្រួសារទាំង ២៥រាជធានី ខេត្ត រួចហើយ និងបានអនុវត្តការបើកប្រាក់របបសន្តិសុខសង្គមតាមប្រព័ន្ធធនាគារចំនួន ២២រាជធានី ខេត្ត នៅសល់ខេត្តព្រៃវែង និងខេត្តកំពត

-ផ្ទេរអតីតយុទ្ធជនតាមមន្ទីរ ស.អ.យ រាជធានីខេត្តចំនួន ១៤០គ្រួសារ

-ទទួលអតីតយុទ្ធជនដែលផ្ទេរពីក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃចំនួន ២៦៩នាក់

-ផ្តល់ប្រាក់បូជាសព មួយលើកដំបូង និងប្រាក់ធានា៉ាប់រងសង្គមដល់អតីតយុទ្ធជនចំនួន ៩២នាក់ សរុបជាថវិកាចំនួន ៣១៧.៥២៨.៨១៦៥

តារាងកំណត់ប្រាក់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងគ្រួសារ:

ល.រ	មុខសញ្ញា	ចំនួន	បន្ទុកដែលត្រូវទទួលរបប							ទឹកប្រាក់សរុប
			ឪពុក	ម្តាយ	ប្រពន្ធ	អា.ព្យា	កូន	អ្នកបម្រើ	សរុប	
១	ជនពលី	៦	៦	១០	៩	១	៦	-	៣២	២២៣.៦០០៥
២	ជនមរណ:	៣៩	២	៤	៣៧	២	១២	-	៥៧	៣៨២.០០០៥
៣	ជនពិការ	-	-	-	-	-	-	-	-	-
៤	និវត្តជន	១០០	-	-	៩៦	-	២៥	-	១២១	៦៥.៩២៧.៣៨៩៥
៥	ជនបាត់បង់	-	-	-	-	-	-	-	-	-
សរុប		**១៤៥**	**៨**	**១៤**	**១៤២**	**៣**	**៤៣**	**-**	**២១០**	**៦៦.៥៣២.៩៨៩៥**

(ប្រភពៈបេឡាជាតិអតីតយុទ្ធជន)

តារាងលុបឈ្មោះអតីតយុទ្ធជន និងគ្រួសារចេញពីបញ្ជីបើកប្រាក់ប្រចាំខែ:

ល.រ	មុខសញ្ញា	ចំនួន	បន្ទុកដែលត្រូវកាត់ចេញ							ទឹកប្រាក់សរុប
			ឪពុក	ម្តាយ	ប្រពន្ធ	អា.ព្យា	កូន	អ្នកបម្រើ	សរុប	
១	ជនពលី	៨០	១៤៩	១៩២	២១២	-	៣១៥	-	៨៦៨	៤.៨៨៣.២០០៥
២	ជនមរណ:	៦	៣	២	៥	-	១៥	-	២៥	១៦៦.០០០៥
៣	ជនពិការ	២៣	-	-	៨៥	-	៤៩៤	១	៥៨០	៨.៥១៦.៧៥៤៥
៤	និវត្តជន	៣	-	-	១	-	-	-	១	១.៣៧៥.២៣០៥
៥	ជនបាត់បង់	-	-	-	-	-	-	-	-	-
សរុប		**២២៤**	**១៥២**	**១៩៤**	**៣០៣**	**-**	**៨២៤**	**១**	**១.៤៧៤**	**១៤.៩៤១.១៨៤៥**

(ប្រភពៈបេឡាជាតិអតីតយុទ្ធជន)

តារាងលុបឈ្មោះអតីតយុទ្ធជន និងគ្រួសារ និងទទួលស្គាល់ជាជនពលី និងមរណ:វិញ:

ល.រ	មុខសញ្ញា	ចំនួន	បន្ទុកដែលទទួលប្រាក់ឧបត្ថម្ភប្រចាំខែ							ទឹកប្រាក់សរុប
			ឪពុក	ម្តាយ	ប្រពន្ធ	អា.ព្យា	កូន	អ្នកបម្រើ	សរុប	
១	ជនពិការ	៦	-	-	៥	-	៦	១	១២	១.៣៦០.៨២៥៥
២	និវត្តជន	៣៥	-	-	៣៤	-	៣៧	-	៧១	១២.៩៨២.៤៤៦៥
៣	ជនបាត់បង់	៤	-	-	៤	-	៤	១	៩	១.៣៩២.៨៩៣៥
សរុប		**៤៥**	**-**	**-**	**៤៣**	**-**	**៤៧**	**២**	**៩២**	**១៥.៧៣៦.១៦៤៥**

(ប្រភពៈបេឡាជាតិអតីតយុទ្ធជន)

ស្ថិតិអតីតយុទ្ធជន និងគ្រួសារ ដែលកំពុងទទួលប្រាក់របបសន្តិសុខសង្គមក្នុងខែមេសា ឆ្នាំ២០១៤:

ល.រ	មុខសញ្ញា	ចំនួន	បន្ទុកដែលត្រូវទទួលរបប							ទឹកប្រាក់សរុប
			ឪពុក	ម្តាយ	ប្រពន្ធ	អា.ព្យា	កូន	អ្នកបម្រើ	សរុប	
១	ជនពលី	៣៣.៥៩០	១០.៨៨១	១៧.៩៥៦	២៣.០៥៧	១៩៧	២១.៥៨០		៧៣.៦៧១	៥៤១.១០៣.៨៤០៥
២	ជនមរណ:	៤.៩០៩	៩៦៣	១.៩៧៨	៣.៨២៩	៤៩	៥.៥១៥		១២.៣៣៤	៨៩.៤៥០.៩០០៥
៣	ជនពិការ	២៧.២៤៩			២៤.១៤១		២៣.៨៥២	១.៣១៥	៤៩.៣០៨	១០.០១០.១០៤.១៨២៥
៤	និវត្តជន	២៣.៥៨២			២០.៨៥០		១៧.៩៩៥		៣៨.៨៤៥	១០.៣៦០.៨៦៥.៦៧៨៥
៥	ជនបាត់បង់	១.៧០៨			១.៣៨៥		១.៤១៣	១៥	២.៨១៣	៦០០.៦១៧.៧១៤៥
សរុប		**៩១.០៣៨**	**១១.៨៤៤**	**១៩.៩៣៤**	**៧៣.២៦២**	**២៤៦**	**៧០.៣៥៥**	**១.៣៣០**	**១៧៦.៩៧១**	**២១.៦០២.១៤២.៣១៤៥**

(ប្រភពៈបេឡាជាតិអតីតយុទ្ធជន)

ខ-ការងារអតីតយុទ្ធជន

-ក្នុងខែមេសា ឆ្នាំ២០១៤នេះ គណ:អចិន្ត្រៃយ៍នៃគណ:កម្មាធិការកណ្តាល ស.អ.ក បានទទួលសំណុំបែបបទស្នើសុំប្រាក់បេឡាមរណសង្គ្រោះពី ស.អ.ក រាជធានី ខេត្ត ក្រសួង ស្ថាប័នចំនួន ២៩សព

-គិតពីឆ្នាំ២០០៨ មកដល់ខែមេសា ឆ្នាំ២០១៤នេះ សំណុំបែបបទស្នើសុំប្រាក់ ប.ម.ស សរុបចំនួន ៥.២២៨សព និងបានចេញសេចក្តីសម្រេចស្តីពីការប្រគល់ថវិកា ប.ម.ស ជូនសមាជិក ស.អ.ក ចំនួន ៣.៩៧៣សព នៅសល់ ១.២៥៥សព

-ស.អ.ក បានប្រគល់ផ្ទះចំនួន ០៣ខ្នង ជូនគ្រួសារជនពិការក្រីក្រនៅខេត្តកំពង់ឆ្នាំង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម វង សូត រដ្ឋមន្ត្រីក្រសួង ស.អ.យ។ គិតមកដល់ពេលនេះ ស.អ.ក បានសាងសង់ផ្ទះជូនអតីតយុទ្ធជនសរុបចំនួន ២១២ខ្នង

-គិតពីឆ្នាំ២០១០ មកដល់មីនា ឆ្នាំ២០១៤នេះ គណៈកម្មាធិការអន្តរក្រសួងបានទទួលបញ្ជីឈ្មោះ និងសំណុំបែបបទអ្នកស្នើសុំសម្បទានដីសង្គមកិច្ចសរុបចំនួន ១៥.០៩២គ្រួសារ និងបានបញ្ជូនបញ្ជីឈ្មោះ និងសំណុំបែបបទស្នើសុំសម្បទានដីសង្គមកិច្ច ទៅគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិចំនួន ១៣.២៦៥គ្រួសារ

-បាននិងកំពុងរៀបចំកែសម្រួលសមាសភាពនៃសេចក្តីសម្រេច ស្តីពីការបង្កើតគណៈកម្មាធិការអន្តរក្រសួងសម្រាប់កំណត់អត្តសញ្ញាណកងកម្លាំងប្រដាប់អាវុធចូលនិវត្តន៍ ចូលបាត់បង់សមត្ថភាពការងារ ពិការ និងគ្រួសារយុទ្ធជនពលី មរណៈដែលត្រូវទទួលសម្បទានដីសង្គមកិច្ច។

៦.ការងារអាទិភាពទី៦

ពង្រឹងពង្រីកសមត្ថភាពស្ថាប័ន ភាពជាដៃគូ ក្បៀរគរប្រភពធនធាន បង្កើនប្រសិទ្ធភាពនៃសេវាសង្គមកិច្ច

១.ការងាររដ្ឋបាល និងបុគ្គលិក

ក.ការងាររដ្ឋបាល

-បានរក្សាទុក និងតម្កល់លិខិតបទដ្ឋានគតិយុត្ត មានសណ្តាប់ធ្នាប់ របៀបរៀបរយ ត្រឹមត្រូវ និងលាក់ការណ៍សម្ងាត់

-បានទទួលលិខិតចូលចំនួន ៣៨៨ច្បាប់ និងបញ្ជូនលិខិតចេញចំនួន ៤៧៩ច្បាប់

-បានចេញលិខិតបេសកកម្មចំនួន ៥៦ដង។

ខ.ការងារបុគ្គលិក

-ក្របខ័ណ្ឌមន្ត្រីរាជការសរុប ១.៥៣២នាក់ (ថ្នាក់ជាតិ ៥៣៥នាក់ និងក្រោមជាតិ ៩៩៧នាក់)

-បុគ្គលិកជាប់កិច្ចសន្យាសរុប ៦៧៨នាក់ (ថ្នាក់ជាតិ ២១៨នាក់ និងក្រោមជាតិ ៤៦០នាក់)

-តែងតាំង និងប្រគល់ភារកិច្ច ០៤នាក់

-តែងតាំងទីប្រឹក្សាអមក្រសួងចំនួន ០៤នាក់

-លុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌចំនួន ០៣នាក់ (លាឈប់ចំនួន និងមរណភាពចំនួន ០២នាក់)។

គ.ការងារបៀវត្សរ៍

-រៀបចំប្រាក់បៀវត្សរ៍ប្រចាំខែជូនមន្ត្រីរាជការ បានទាន់ពេលវេលា

-រៀបចំបៀវត្សរ៍ជូនមន្ត្រីតែងតាំងថ្មី ជំនួយឯកឧត្តមរដ្ឋមន្ត្រី និងទីប្រឹក្សាអមក្រសួងចំនួន ១៤នាក់

-រៀបចំប្រាក់បំណាច់មុខងារជូនមន្ត្រីតាំងស៊ីប់ចំនួន ០៦នាក់

-រៀបចំប្រាក់បៀវត្សជូមន្ត្រីរាជការដែលទើបផ្ទេរចូលថ្មីចំនួន ០៤នាក់

-ផ្តាច់បផវត្សរ៍ជូនមន្ត្រីរាជការចេញពីតារាងបៀវត្សចំនួន ០១នាក់

-បញ្ចូលអ្នកក្នុងបន្ទុកជា កូនចំនួន ០៥នាក់

-រៀបចំបៀវត្សជូនទីប្រឹក្សាក្រសួងចំនួន ២១នាក់។

ឃ.ការងារអតិវឌ្ឍន៍ធនធានមនុស្ស

-បានផ្សព្វផ្សាយព័ត៌មានស្តីពីការ ផ្តល់អាហារូបករណ៍ និងការជ្រើសរើសមន្ត្រីចូលបម្រើការតាមក្រសួង ស្ថាប័ននានា។

២.ការងារផែនការ ស្ថិតិ និងសរុប

-បានធ្វើបច្ចុប្បន្នភាពជាប្រចាំគេហទំព័ររបស់ក្រសួង ស.អ.យ ដែលមានឈ្មោះ www.mosvy.gov.kh មានលិខិតបទដ្ឋានគតិយុត្ត របាយការណ៍ និងសកម្មភាពផ្សេងៗរបស់ថ្នាក់ដឹកនាំ

-បានពិនិត្យ កែសម្រួលសេចក្តីព្រាងទី២ របាយការណ៍ ស្តីពីការពិនិត្យមើលមុខងារឡើងវិញរបស់ក្រសួង ស.អ.យ

-បានពិនិត្យ កែសម្រួលសេចក្តីព្រាងផែនការយុទ្ធសាស្ត្រ ៥ឆ្នាំ ២០១៤-២០១៨ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

៣.ការងារហិរញ្ញវត្ថុ និងផ្គត់ផ្គង់

ក.ការងារបើកផ្គល់

-ការគ្រប់គ្រង និងការបើកផ្តល់បានអនុវត្តត្រឹមត្រូវ និងទាន់ពេលវេលា ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ មានប្រសិទ្ធភាព តម្លាភាព

-បានបើកផ្តល់ប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភបេសកកម្មក្នុង និងក្រៅប្រទេស ប្រាក់ចូលរួមប្រជុំថ្នាក់ជាតិ អន្តរជាតិ ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងភ្នាក់ងារជាតិជាប់កិច្ចសន្យា ផ្តល់ប្រាក់រៀបចំប្រារព្ធពិធីបុណ្យជាតិ អន្តរជាតិ ពិធីសម្ពោធផ្សេងៗ ផ្តល់ប្រាក់ឧបត្ថម្ភជូនមជ្ឈមណ្ឌលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង និងអង្គការដៃគូ

ខ.ការងារលទ្ធកម្ម ជួសជុល សាងសង់ ផ្គត់ផ្គង់សម្ភារៈ បរិក្ខារ សង្ហារឹម និងប្រេងឥន្ធនៈ

-បានផ្គត់ផ្គង់សម្ភារៈ បរិក្ខារ សង្ហារឹម ការជួសជុល និងប្រេងឥន្ធនៈ ជូនថ្នាក់ដឹកនាំ និងអង្គភាពក្រោមឱវាទ បានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព។

៤.ការងារសហប្រតិបត្តិការអន្តរជាតិ អាស៊ាន និងពិធីការ

-បានចុះកិច្ចព្រមព្រៀងគម្រោងសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ ចំនួន ០២គម្រោង។ បច្ចុប្បន្ន ក្រសួងសហការជាមួយអង្គការចំនួន ១៥៩ ដែលមានថវិការសរុបចំនួន ១៦៦.២៤៦.៩៣៧,២៦ដុល្លារសហរដ្ឋអាមេរិក ក្នុងនោះអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកចំនួន ៥៥អង្គការ មានគម្រោងទឹកប្រាក់សរុបចំនួន ៥០.៩១៩.៥២៤,៦៩ដុល្លារសហរដ្ឋអាមេរិក

-បានសម្របសម្រួល ស្នើសុំស្លាកលេខយានយន្តប្រភេទអង្គការចំនួន ០១ករណី សរុប ០១គ្រឿង

-បានសម្របសម្រួលការនាំចូលសម្ភារ ឧបករណ៍ដែលការបង់ពន្ធជាបន្ទុករបស់រដ្ឋជូនអង្គការចំនួន ០១ករណី

-បានរៀបចំសាលប្រជុំ និងសម្របសម្រួលក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន ០៥ដង។

II-ទិសដៅអនុវត្តបន្ត

១.អភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះនិងជាយរងគ្រោះ និងកិច្ចការគ្រួសារ

-ស្រង់ស្ថិតិប្រជាជនរងគ្រោះ និងផ្តល់ជំនួយសង្គ្រោះបន្ទាន់

-ក្តាប់ស្ថិតិជនអនាថា នៅតាមរាជធានី ទីក្រុង ទីប្រជុំជននានា និងទប់ស្កាត់ការហូរចូលមកទីក្រុង និងទីប្រជុំជន ឬឆ្លងដែនទៅកាន់ប្រទេសជិតខាងនិងការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព

-ត្រៀមរៀបចំទិវាអន្តរជាតិស្តីពីគ្រួសារ ១៥ឧសភា

-បន្តសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ដើម្បីអប់រំ បង្ការ ទប់ស្កាត់ ស្តារនីតិសម្បទា សមាហរណកម្ម ប៉ាន់ប្រមាណ និងតាមដានជនរងគ្រោះដោយអំពើជួញដូរមនុស្ស

-បន្តរៀបចំឯកសារកំណត់អត្តសញ្ញាណ និងការបញ្ជូនជនរងគ្រោះដោយអំពើជួញដូរ និងអំពើអាជីវកម្មផ្លូវភេទ

-បន្តរៀបចំសេចក្តីព្រាងឧបករណ៍សម្រាប់វាស់វែងគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារជនរងគ្រោះ និងការថែទាំជនរងគ្រោះនៅក្នុងមណ្ឌល។

២.អភិវឌ្ឍសុខុមាលភាពកុមារ និងយុវនីតិសម្បទា

-បន្តចេញប្រកាសបញ្ចេញបញ្ចូលកុមារកំព្រាពីមណ្ឌលកុមារកំព្រារបស់រដ្ឋនិងអង្គការ និងផ្សព្វផ្សាយអំពីទម្រង់ក្នុងការបញ្ចេញបញ្ចូលកុមារក្នុងមណ្ឌលរដ្ឋ និងអង្គការ

-បន្តរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីនីតិវិធីអនុវត្តគោលនយោបាយ ស្តីពីការថែទាំជំនួសចំពោះកុមារដល់ប្រធានមន្ទីរ ស.អ.យ ជនបង្គោលកិច្ចការនារី និងកុមារឃុំ សង្កាត់ និងសមាជិកគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់

-បន្តពិនិត្យ កែសម្រួលសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការគ្រប់គ្រងមណ្ឌលកុមារកំព្រា

-រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់កុមារដែលជាកម្មវត្ថុស្នុំកូនអន្តរប្រទេស និងកុមារដែលត្រូវបានគេសុំ និងធ្វើបច្ចុប្បន្នភាពគេហទំព័ររបស់រដ្ឋបាលស្នុំកូនអន្តរប្រទេស

-រៀបចំទម្រង់បែបបទសម្រាប់ដំណើរការស្នុំកូនអន្តរប្រទេស

-រៀបចំចងក្រង បោះពុម្ពកម្រងឯកសាររបស់រដ្ឋបាលស្នុំកូនអន្តរប្រទេស

-បញ្ជូនមន្ត្រីរដ្ឋបាលស្មុំកូនអន្តរប្រទេសទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីស្មុំកូនអន្តរប្រទេសនៅប្រទេសហ្វីលីពីន

-បន្តសហការជាមួយស្ថាប័នមានសមត្ថកិច្ច អាណាព្យាបាល ដើម្បីបញ្ជូន ទទួលមកថែទាំ អប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន

-បន្តស្វែងរកដៃគូដើម្បីអភិវឌ្ឍវិស័យយុវនីតិសម្បទា និងពង្រឹងសេវាស្តារនីតិសម្បទាជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនស្នាក់នៅក្នុងមជ្ឈមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ

-បន្តផ្សព្វផ្សាយអំពីផលប៉ះពាល់ និងការបង្កគ្រោះថ្នាក់ដោយសារគ្រឿងញៀន និងសិទ្ធិកុមារទំនាស់នឹងច្បាប់ នៅតាមរាជធានី ខេត្ត និងតាមសហគមន៍

-បន្តរៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីរបបគោលនយោបាយជនរងគ្រោះដោយគ្រឿងញៀនស្នាក់នៅក្នុងមជ្ឈមណ្ឌលរដ្ឋ

-បន្តរៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការស្តារនីតិសម្បទា និងសមាហរណកម្មអនីតិជនប្រព្រឹត្តបទល្មើសនៅមណ្ឌលអប់រំកែប្រែ និងពន្ធនាគារ

-បន្តរៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីវិធីសាស្ត្រព្យាបាល និងគ្រប់គ្រងវិធានការព្យាបាល និងស្តារនីតិសម្បទាភាពញៀនគ្រឿងញៀន

-រៀបចំប្រកាសអន្តរក្រសួង ស្តីពីការចិញ្ចឹមបីបាច់ថែរក្សាកូនតាមម្តាយនៅក្នុងមណ្ឌលអប់រំកែប្រែ និងពន្ធនាគារដែលមានអាយុចាប់ពី ៣ (បី)ឆ្នាំឡើងទៅ

-បន្តចេញប្រកាសបញ្ចេញបញ្ចូលជនរងគ្រោះ ពីមជ្ឈមណ្ឌលយុវនីតិសម្បទាអ្នកញៀនគ្រឿងញៀន

-បន្តរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន

-បន្តរៀបចំសេចក្តីព្រាងផែនការជាតិអភិវឌ្ឍន៍កុមាររយៈពេល ១០ឆ្នាំ ២០១៥-២០២៥

-រៀបចំបង្កើតអនុគណៈកម្មការច្បាប់និងគោលនយោបាយពាក់ព័ន្ធនឹងការការពារ និងអនុគណៈកម្មការពិនិត្យតាមដាន និងធ្វើរបាយការណ៍

-ត្រៀមរៀបចំទិវាកុមារអន្តរជាតិ ១មិថុនា

-រៀបចំបោះពុម្ព និងចែកផ្សាយព្រឹត្តិបត្រស្ថានភាពកុមារលេខទី៣របស់ ក.ជ.ក ដល់ក្រសួង ស្ថាប័ន អង្គការពាក់ព័ន្ធ។

៣-អតិថឌ្ឍសុខុមាលភាពជនពិការ

-ជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការស្របតាមគោលនយោបាយជាតិ ស្តីពីជនពិការ

-បន្តអនុវត្តកម្មវិធីសម្របសម្រួលថ្នាក់ជាតិលើសេវាស្តារលទ្ធភាពពលកម្មនៅសហគមន៍

-បន្តនិរន្តរភាពកម្មវិធីស្តារលទ្ធភាពពលកម្មកាយសម្បទាជូនជនពិការ

-ជំរុញការផ្តល់អត្តសញ្ញាណប័ណ្ណសម្គាល់ប្រភេទ និងកម្រិតពិការភាពជូនជនពិការ

-ជំរុញការផ្តល់របបគោលនយោបាយជួយឧបត្ថម្ភជនពិការក្រីក្រតាមសហគមន៍

-ជំរុញការដាក់បញ្ចូលបញ្ហាពិការភាពទៅក្នុងផែនការអភិវឌ្ឍន៍នានា

-ជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្តដើម្បីជំរុញដំណើរការរដ្ឋបាលសិទ្ធិជនពិការ

-ជំរុញអនុវត្តនីតិវិធីធ្វើអធិការកិច្ចតាមក្រសួង ស្ថាប័នរដ្ឋ និងបន្តផ្សព្វផ្សាយដល់វិស័យឯកជន ក្នុងការទទួលជនពិការចូលបម្រើការងារ (រដ្ឋ ២% ឯកជន ១%)

-បន្តរៀបចំនីតិវិធីសម្រាប់សេវាព្យាបាលដោយចលនា

-បន្តផលិត ផ្គត់ផ្គង់ឧបករណ៍សិប្បនិម្មិត ដើម្បីស្តារកាយសម្បទាជូនជនពិការដោយឥតគិតថ្លៃ

-បន្តការងារបណ្តុះបណ្តាលវិជ្ជាជីវៈ ដោះស្រាយការងារ និងមុខរបរជូនជនពិការ

-ជំរុញការរៀបចំនីតិវិធីនៃការធ្វើអធិការកិច្ច វិធានការព្រមានដាក់កំហិត និងផាកពិន័យផ្សេងៗចំពោះក្រសួង ស្ថាប័ន និងក្រុមហ៊ុនឯកជនដែលមិនបានច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ

-ចុះធ្វើអធិការកិច្ចនៅមជ្ឈមណ្ឌលស្តារលទ្ធភាបពលកម្មកាយសម្បទា

-បន្តពង្រីកការដាក់ហិបមូលនិធិជនពិការនៅតាមទីតាំងផ្សេងៗទៀត នៅតាមរាជធានី ខេត្ត

-ត្រៀមរៀបចំពិធីប្រកាស ផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រជាតិ ស្តីពីពិការភាព ២០១៤-២០១៨

-រៀបចំក្រុមការងារសម្រាប់រៀបចំរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញា ស្តីពីសិទ្ធិជនពិការ។

៤-អភិវឌ្ឍសុខុមាលភាពមនុស្សចាស់

-ជំរុញធ្វើបច្ចុប្បន្នភាពទិន្នន័យសមាគមមនុស្សចាស់

-ពង្រឹងសកម្មភាពសមាគមមនុស្សចាស់ដែលមានស្រាប់ និងជំរុញការបង្កើតសមាគមមនុស្សចាស់នៅតាមរាជធានី ខេត្ត

-បន្តរៀបចំសេចក្តីព្រាងថ្មី ស្តីពីគោលនយោបាយជាតិកម្ពុជាដើម្បីមនុស្សចាស់

-បន្តរៀបចំផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីការថែទាំមនុស្សចាស់តាមលំនៅឋាននៅកម្ពុជា

-បន្តក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ ដើម្បីលើកកម្ពស់សុខុមាលភាពមនុស្សឲ្យកាន់តែប្រសើរឡើង។

៥-អភិវឌ្ឍរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

-បន្តចេញប្រកាសទទួលស្គាល់អតីតមន្ត្រីរាជការស៊ីវិលដែលផ្ទេរមកក្រសួង ស.អ.យ

-បន្តធ្វើបច្ចុប្បន្នភាពសិទ្ធិវន្ត ប.ជ.ស ដែលទើបចូលនិវត្តន៍ និងជំរុញការបើកផ្តល់របបសន្តិសុខសង្គមតាមប្រព័ន្ធធនាគារ

-បន្តពិនិត្យ កែសម្រួលប្រាក់របបសន្តិសុខសង្គមជូនដល់អតីតមន្ត្រីរាជការស៊ីវិល

-ជំរុញការគ្រប់គ្រងទិន្នន័យមន្ត្រីរាជការស៊ីវិលជាមួយក្រសួងមុខងារសាធារណៈ ដើម្បីដាក់មន្ត្រីរាជការស៊ីវិលចូលនិវត្តន៍ឲ្យទទួលបានលទ្ធផលប្រកបដោយប្រសិទ្ធភាព

-ជំរុញរៀបចំ និងដាក់ឲ្យដំណើរការសាខា ប.ជ.ស ក្រុង ស្រុក ខណ្ឌ នៅតាមរាជធានី ខេត្ត

៦-អភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន

-បន្តចេញប្រកាសទទួលស្គាល់ អតីតយុទ្ធជនដែលផ្ទេរពីក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ លុបមុខសញ្ញាដែលផុតសុពលភាព បន្ទុកផុតសុពលភាព

-បន្តរៀបចំកែសម្រួលប្រាក់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងគ្រួសារ

-ពង្រឹងការបើកផ្តល់ប្រាក់របបគោលនយោបាយដល់មុខសញ្ញាអតីតយុទ្ធជន និងគ្រួសារ

-បន្តរៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកំណត់អត្រាភាគទានសម្រាប់ទ្រទ្រង់បេឡាជាតិអតីតយុទ្ធជន

-ជំរុញការរៀបចំលិខិតបទដ្ឋាន និងនីតិវិធីផ្សេងៗសម្រាប់ដំណើរការ ប.ជ.អ

-បន្តធ្វើបច្ចុប្បន្នភាពអតីតយុទ្ធជនដែលផ្ទេរពីក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ

-រៀបចំប្រកាសស្តីពីការផ្ទេរការគ្រប់គ្រង និងផ្ទេរការអនុវត្តរបបសន្តិសុខសង្គមរបស់អតីតយុទ្ធជនមន្ទី ស.អ.យ រាជធានី ខេត្ត មក ប.ជ.អ

-បន្តរៀបចំ និងដាក់ឲ្យដំណើរការការិយាល័យ និងសាខា ប.ជ.អ នៅរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ

-ជំរុញរៀបចំអនុក្រឹត្យ ស្តីពីការកំណត់អត្រាភាគទានដើម្បីទ្រទ្រង់បេឡាជាតិអតីតយុទ្ធជន

-ពង្រឹងកិច្ចសហការជាមួយធនាគារដៃគូ ក្នុងការបើកផ្តល់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន

-ជំរុញការបើកផ្តល់ប្រាក់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងគ្រួសារ តាមរយៈប្រព័ន្ធធនាគារនៃខេត្តដែលបានធ្វើបច្ចុប្បន្នភាពរួច

-ចុះធ្វើអធិការកិច្ចមុខសញ្ញាដែលមិនមកធ្វើបច្ចុប្បន្នភាព និងមុខសញ្ញាដែលធ្វើបច្ចុប្បន្នភាពហើយមិនមកបើកប្រាក់ពីធនាគារ

-បន្តទទួល ពិនិត្យ និងផ្ទៀងផ្ទាត់លើសំណុំបែបបទស្នើសុំប្រាក់បេឡាមរណាសង្គ្រោះ

-ពង្រឹងការអនុវត្តបេឡាមរណាសង្គ្រោះ ស.អ.ក ស្របតាមគោលការណ៍នៃលក្ខន្តិកៈ ស.អ.ក ឲ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព

-ចេញសេចក្តីជូនដំណឹងស្តីពីមរណភាពសមាជិកសមាគមអតីតយុទ្ធជនកម្ពុជាចំនួន ៦០សព/ខែ

-បំផុសចលនា ៣ពូកែ ក្នុងអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន

-ពង្រឹងការអនុវត្តគោលការណ៍កំណត់អត្តសញ្ញាណអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ ដែលត្រូវទទួលសម្បទានដីសង្គមកិច្ច ដោយឈរលើគោលការណ៍សមធម៌

-ជំរុញសកម្មភាពការងាររបស់គណៈកម្មាធិការអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជនឃុំ សង្កាត់

-បន្តផ្សព្វផ្សាយដល់មន្ត្រីរាជការស៊ីវិលក្នុងក្រសួង ស.អ.យ ឲ្យដាក់ពាក្យចូលជាសមាជិក ស.អ.ក នៅតាមនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួង។

៧.បង្កើតប្រព័ន្ធសន្តិសុខសង្គមទូលំទូលាយសម្រាប់ប្រជាជនកម្ពុជា

-ជំរុញឲ្យមានសិក្សាបន្ថែមលើសេចក្តីព្រាងច្បាប់ ស្តីពីរបបសន្តិសុខសង្គមសម្រាប់ប្រជាជនកម្ពុជា

-រៀបចំចងក្រងលិខិតបទដ្ឋានគតិយុត្តគាំទ្រនានា។

៨.អភិវឌ្ឍសមត្ថភាពស្ថាប័ន និងពង្រឹងភាពជាដៃគូ

-បន្តអនុវត្តគោលការណ៍ពង្រឹងសមត្ថភាពស្ថាប័ន មន្ត្រីរាជការស៊ីវិល និងការគ្រប់គ្រងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល

-បន្តរៀបចំឯកសារដំឡើងឋានន្តរស័ក្តិ ថ្នាក់ និងប្រាក់បំណាច់មុខងារ និងប្រាក់បំណាច់ផ្សេងៗជូនមន្ត្រីរាជការស៊ីវិល

-ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការ តាមរយៈការអនុវត្តច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល បទបញ្ជាផ្ទៃក្នុង និងរបៀបរបបធ្វើការឲ្យបានហ្មឹងម៉ាត់

-តាមដានដំណើរការរៀបចំបើកប្រាក់បៀវត្សរ៍មន្ត្រីក្រសួង ស.អ.យ តាមរយៈប្រព័ន្ធធនាគារ

-បញ្ចប់ការរៀបចំរបាយការណ៍ស្តីពីការពិនិត្យមើលមុខងារឡើងវិញរបស់ក្រសួង ស.អ.យ

-បញ្ចប់ការរៀបចំផែនការយុទ្ធសាស្ត្រឆ្នាំ២០១៤-២០១៨ របស់ក្រសួង ស.អ.យ

-បន្តធ្វើបច្ចុប្បន្នភាពព័ត៌មានស្តីពីលទ្ធផលការងារ និងសកម្មភាពថ្នាក់ដឹកនាំរបស់ក្រសួង នៅក្នុងគេហទំព័ររបស់ក្រសួង (www.mosvy.gov.kh)

-ជំរុញការបើកផ្តល់ប្រាក់បៀវត្សរ៍ និងការផ្គត់ផ្គង់ផ្សេងៗ ឲ្យបានទាន់ពេលវេលា មានប្រសិទ្ធភាព និងតម្លាភាព

-រៀបចំផែនការថវិកា ០៣ឆ្នាំរំកិល ២០១៥-២០១៧

-ធ្វើការណែនាំបំពេញបន្ថែមនូវបច្ចេកទេសគ្រប់គ្រងថវិការដ្ឋ យកចិត្តទុកដាក់ដល់ការត្រួតពិនិត្យបញ្ជីគណនេយ្យ និងពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

-ជំរុញអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ

-ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងបន្តនិរន្តរភាពការងាររបស់អង្គការ

-ពង្រឹងពង្រីកទំនាក់ទំនងសហប្រតិបត្តិការទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេសនានា សហគមន៍អាស៊ាន និងសហគមន៍អន្តរជាតិ

-តាមដានរបាយការណ៍តាមអង្គភាពចំណុះក្រសួង ដើម្បីពង្រឹងប្រសិទ្ធភាពការងារ។

រាជធានីភ្នំពេញ,ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៤

ដ្ឋមន្ត្រី

ទ្ធ សូត